ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

# កំណត់ហេតុ
## កិច្ចប្រជុំត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី ការអនុវត្តយុទ្ធសាស្ត្របង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន

ថ្ងៃពុធ ១រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស ពីរពាន់ប្រាំរយហុកសិបប្រាំបួន ត្រូវនឹងថ្ងៃទីប្រាំបី ខែតុលា ឆ្នាំពីរពាន់ម្ភៃប្រាំ វេលាម៉ោងប្រាំបួន និងសូន្យនាទីព្រឹក នៅទីស្តីការក្រសួងមហាផ្ទៃ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានរៀបចំកិច្ចប្រជុំ «ត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី ការអនុវត្តយុទ្ធសាស្ត្របង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន» ជាមួយបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមជអធិបតីភាព **លោកជំទាវ ឧត្តមសេនីយ៍ ទោ ប៊ុណ្ណា សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ** តំណាងដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** ។

គោលបំណង នៃការរៀបចំកិច្ចប្រជុំពេលនេះ គឺដើម្បីឆ្លងសេចក្តីព្រាងរបៀបវារៈ សម្រាប់រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី «ការអនុវត្តយុទ្ធសាស្ត្របង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន» ដែលនឹងប្រារព្ធធ្វើនៅថ្ងៃទី១៣-១៤ ខែតុលា ឆ្នាំ២០២៥ នៅទីស្តីការក្រសួងមហាផ្ទៃ។

**ក. សមាសភាពចូលរួម ៖**

- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- តំណាងក្រសួងអប់រំយុវជន និងកីឡា
- តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- តំណាង ក្រសួងពាណិជ្ជកម្ម
- តំណាង ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- តំណាង ក្រសួងធម្មការ និងសាសនា
- តំណាង អគ្គស្នងការដ្ឋាននគរបាលជាតិ (នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន)
- តំណាង អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- ឯកឧត្តម លោកជំទាវ អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
- លោកប្រធាន អនុប្រធាននាយកដ្ឋាន លោកទីប្រឹក្សា នាយ នាយរងការិយាល័យ និងមន្ត្រីបច្ចេកទេស នៃអគ្គលេខាធិការ ដ្ឋាន គ.ជ.ប.ជ សរុបចំនួន ៣០រូប ស្រី០៤រូប។

**ខ. មតិស្វាគមន៍ និងដឹកនាំកិច្ចប្រជុំ ៖**

ជាកិច្ចចាប់ផ្ដើម លោកជំទាវឧត្ដមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ **សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានសម្ដែងនូវការស្វាគមន៍ ចំពោះ ឯកឧត្ដម លោកជំទាវ លោក លោកស្រី ដែលតំណាងឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចំណាយពេលវេលា អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សានៅពេលនេះ។

លោកជំទាវ ក៏បានបញ្ជាក់ពីគោលបំណងដែលបានរៀបចំកិច្ចប្រជុំនាពេលនេះគឺ ដើម្បីដាក់ឆ្លងរបៀបវារៈនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្ដីពី «ការអនុវត្តយុទ្ធសាស្ត្របង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ប្រកបដោយប្រសិទ្ធភាព ដើម្បីកាត់បន្ថយចំណាកស្រុកដោយប្រថុយប្រថាន» ដែលគ្រោងនឹងប្រារព្ធធ្វើរយៈពេលពីរថ្ងៃ គឺពីថ្ងៃទី១៣-១៤ ខែតុលា ឆ្នាំ២០២៥ ខាងមុខនេះ។ លោកជទាំវ ប្រធានអង្គប្រជុំ បានបញ្ជាក់បន្ថែមថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានយុទ្ធសាស្ត្រចំនួនបួន គឺ៖ ការបង្ការទប់ស្កាត់ ការអនុវត្តច្បាប់ កិច្ចការពារជនរងគ្រោះ និងការងារច្បាប់ គោលនយោបាយ ដែលជាយុទ្ធសាស្ត្រស្នូល គាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រទាំងបីខាងលើ ប៉ុន្តែក្នុងនោះយើងជ្រើសរើសយកយុទ្ធសាស្ត្រទីមួយ គឺ ការបង្ការ ទប់ស្កាត់ ជាយុទ្ធសាស្ត្រអាទិភាព។ បន្ទាប់មក លោកជំទាវ ក៏បានចាត់តាំងឯកឧត្ដមឧត្ដមសេនីយ៍ទោ កែវ សុវណ្ណារ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ សម្របសម្រួល និងដាក់ជូនសេចក្ដីព្រាងរបៀបវារៈ ដើម្បីអង្គប្រជុំជជែកពិភាក្សា។

**គ. មតិចូលរួម ៖**

របៀបវារៈថ្ងៃទី០១៖ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥

-តំណាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សុំប្ដូរពាក្យ *ស្ថានភាព* ទៅ *បច្ចុប្បន្នភាព*

-តំណាងក្រសួងអប់រំ យុវជន និងកីឡា ចង់ដឹងពីប្រធានបទលម្អិត ដើម្បីរៀបចំបទបង្ហាញ ឬរបាយការណ៍ និងសុំកំណត់រយៈពេលជាក់លាក់ សម្រាប់ក្រុមនីមួយៗក្នុងការធ្វើបទបង្ហាញរបស់ខ្លួន

-តំណាងក្រសួងធម្មការ និងសាសនា នឹងផ្ដល់ជារបាយការណ៍ស្ដីពី ការបញ្ជ្រាបការយល់ដឹងអំពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស

-តំណាងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម ថានឹងផ្ដល់ជាបទបង្ហាញខ្លី អំពីវិស័យរបស់ខ្លួនផងដែរ។

ជាការឆ្លើយតប លោកជំទាវ ប្រធានកិច្ចប្រជុំ បានសម្រេចកំណត់រយៈពេលជូនក្រុមនីមួយៗធ្វើបទបង្ហាញ រយៈពេលពី ៥ ទៅ ១០ នាទី តាមលទ្ធភាពជាក់ស្ដែងរបស់ក្រុមនីមួយៗ និងសមាជិកក្នុងកិច្ចប្រជុំបានឯកភាពតាមរបៀបវារៈដែលបានគ្រោងទុក។

របៀបវារៈថ្ងៃទី០២៖ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥

ចំពោះរបៀបវារៈថ្ងៃទីទី០២ សមាជិក សមាជិកា អង្គប្រជុំបានឯកភាពតាមសេចក្ដីព្រាងរបៀបវារៈ ដែលបានគ្រោងទុក និងសុំធ្វើកែសម្រួលអក្ខរាវិរុទ្ធ និងខ្លឹមសារខ្លះៗទៅលើចំណុចមួយចំនួន

**ឃ. លទ្ធផលរួមនៃកិច្ចប្រជុំ ៖**

សមាជិក សមាជិកា នៃកិច្ចប្រជុំបានឯកភាពទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

- ឯកភាពលើប្រធានបទ និងខ្លឹមសារនៃសាលា ដែលគ្រោងនឹងរៀបចំនាពេលខាងមុខ
- រៀបចំធ្វើបទបង្ហាញឱ្យទាន់ពេលវេលា ដោយយកទិន្នន័យក្នុងឆ្នាំ២០២៥ (០៨ខែ ទៅ ០៩ខែ)
- ទទួលយកការធ្វើបទបង្ហាញតាមការចាត់តាំងរបស់កម្មវិធី និងរយៈពេលដែលបានផ្ដល់ជូន

ជាថ្មីម្តងទៀត លោកជំទាវ ប្រធានអង្គប្រជុំ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ សមាជិក សមាជិកា នៃកិច្ចប្រជុំទាំងអស់ និង សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ព្រមទាំងទទួលបានជោគជ័យគ្រប់ភារកិច្ច។

កិច្ចប្រជុំពិភាក្សា បានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងសាមសិបនាទីព្រឹក ថ្ងៃ ខែ ឆ្នាំ ដដែល ប្រកបដោយបរិយាកាសរីករាយ និងភាពស្និទ្ធស្នាល។

ថ្ងៃព្រហស្បតិ៍ ២រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩

រាជធានីភ្នំពេញថ្ងៃទី ៩ ខែតុលា ឆ្នាំ២០២៥

អ្នកធ្វើកំណត់ហេតុ

វរសេនីយ៍ទោ ចេក វណ្ណា

បានឃើញ និងសូមគោរពជូន

លោកជំទាវអគ្គលេខាធិការ មេត្តាជ្រាប

រាជធានីភ្នំពេញ ថ្ងៃទី...១៩...ខែ...តុលា....ឆ្នាំ២០២៥

**ប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប** ស្អិទ

ឧត្តមសេនីយ៍ទោ.អ៊ុច សម្បត្តិ

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី...១០...ខែ....តុលា...ឆ្នាំ២០២៥

**អគ្គលេខាធិការ គ.ជ.ប.ជ**

ឧត្តមសេនីយ៍ឯកវេជ្ជ.ប៊ុណ្ណ សំខាន់